*បកប្រែក្រៅផ្លូវការ*

**អង្គការសហប្រជាជាតិ** **CEDAW** /C/KHM/CO/3

**អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ**

ចែកចាយទូទៅ
ថ្ងៃទី៣២៥ ខែមករា ឆ្នាំ២០០៦
អត្ថបទដើម: អង់គ្លេស

**គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ**

**សម័យប្រជុំលើកទី៣៤**

ថ្ងៃទី១៦ ខែមករា ដល់ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៦

# សេចក្តីផ្តល់មតិចុងក្រោយរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ : ប្រទេសកម្ពុជា

១- គណៈកម្មាធិការបានពិចារណាលើរបាយការណ៍លើកដំបូងនិងតាមកាលកំណត់លើកទីពីរនិងលើកទីបី (CEDAW/C/KHM/1-3) របស់ប្រទេសកម្ពុជា នាសម័យប្រជុំរបស់ខ្លួនលើកទី៧០៥ និង៧០៦ កាលពីថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៦ (សូមមើល CEDAW/C/SR.705 និង 706)។ បញ្ជីបញ្ហា និងសំណួរផ្សេងៗ របស់គណៈកម្មាធិការមាននៅក្នុងCEDAW/C/ KHM/Q/1-3 និងការឆ្លើយតបរបស់ប្រទេសកម្ពុជាមាននៅក្នុង CEDAW/C/KHM/1-3/Add.1.

## សេចក្តីផ្តើម :

២- គណៈកម្មាធិការស្ញើចសរសើរដល់រដ្ឋភាគីដែលផ្តល់សច្ចាប័នលើអនុសញ្ញាដោយគ្មានខរក្សាទុក ហើយសរសើរផងដែរដល់រដ្ឋភាគីចំពោះរបាយការណ៍លើកដំបូងនិងតាមកាលកំណត់លើកទីពីរនិងលើកទីបី ដែលបានអនុវត្តតាមគោលការណ៍ណែនាំ ទន្ទឹមនឹងនេះ គណៈកម្មាធិការក៏មានការសោកស្តាយផងដែរចំពោះការ

យឺតយ៉ាវ ។ គណៈកម្មាធិការក៏បានសំដែងនូវការស្ញើចសរសើរផងដែរដល់រដ្ឋភាគីចំពោះការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងបញ្ជីបញ្ហា និងសំណួរផ្សេងៗ ដែលបានលើកឡើងដោយក្រុមការងារមុនសម័យប្រជុំ និងចំពោះការរាយការណ៍ផ្ទាល់មាត់ និងការបញ្ជាក់បំភ្លឺឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលគណៈកម្មាធិការបានចោទសួរផ្ទាល់មាត់ ។

៣- គណៈកម្មាធិការស្ញើចសរសើររដ្ឋភាគី ដែលបានបញ្ជូនគណៈប្រតិភូជាន់ខ្ពស់របស់ខ្លួន ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ហើយរួមទាំងតំណាងនានាមកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងតំណាងមកពីក្រសួងផ្សេងៗទៀត ដូចជាក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងអប់រំ ។ គណៈកម្មាធិការសំដែងនូវការស្ញើចសរសើរចំពោះការសន្ទនាដោយចំហ និងក្នុងន័យស្ថាបនា ដែលបានរៀបចំធ្វើឡើងរវាងគណៈប្រតិភូ និង សមាជិកគណៈកម្មាធិការ ។

**ទិដ្ឋភាពវិជ្ជមាន**

៤- គណៈកម្មាធិការកត់សំគាល់ដោយការស្ញើចសរសើរអំពីការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដោយរដ្ឋភាគី ក្នុងគោលបំណងសំរេចឱ្យបាននូវសមភាពខាងយេនឌ័រ និងលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ គណៈកម្មាធិការសូមស្វាគមន៍ការបង្កើតយន្តការជាតិ ដើម្បីភាពជឿនលឿនរបស់ស្ត្រី នោះគឺ ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និងការអនុម័តផែនការជាតិរយៈពេលប្រាំឆ្នាំ ដែលមានឈ្មោះថា " នារីរតនៈ " ដែលផ្តោតជាសំខាន់លើការកសាងសមត្ថភាពស្ត្រី និងការធ្វើសមាហរណកម្មវិស័យយេនឌ័រ ទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣ - ២០០៥ ។

៥- គណៈកម្មាធិការស្នើសុំឱ្យបន្តធ្វើកំណែទម្រង់ច្បាប់ ជាពិសេស ការធ្វើកំណែទម្រង់ក្រមព្រហ្មទណ្ឌ ដើម្បីដាក់បញ្ចូលការផ្តន្ទាទោសចំពោះបទល្មើសនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងស្នើសុំឱ្យពិនិត្យឡើងវិញនូវច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ឆ្នាំ១៩៩៦ ដើម្បីដាក់បញ្ចូលទណ្ឌកម្មទៅលើជនល្មើស និងវិធានការការពារជនរងគ្រោះ ។

៦- គណៈកម្មាធិការសូមស្វាគមន៍ចំពោះការអនុម័ត និងការចូលជាធរមាន កាលពីខែតុលា ឆ្នាំ២០០៥ នៃច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ។

៧- គណៈកម្មាធិការស្នើសុំឱ្យរដ្ឋភាគីខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងដើម្បីធានាឯករាជ្យភាពរបស់តុលាការ ដោយរួមទាំងច្បាប់ស្តីពីការចាត់តាំងតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងការរៀបចំឱ្យមានក្រមសីលធម៌សំរាប់ចៅក្រម ។

៨- គណៈកម្មាធិការក៏សូមស្វាគមន៍ចំពោះហេតុដែលថា ទិន្នន័យខាងស្ថិតិ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីឋានៈរបស់ស្ត្រី បច្ចុប្បន្នមាននៅក្នុងរដ្ឋភាគី ជាពិសេសអត្ថបទបោះពុម្ពផ្សាយដែលមានចំណងជើងថា " ការបែងចែកប្រកបដោយយុត្តិធម៌សំរាប់ស្ត្រី " ។

**វិស័យសំខាន់ៗ នៃការព្រួយបារម្ភ និងអនុសាសន៍**

៩- បើពិនិត្យទៅលើមាត្រា៣១ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញចែងទទួលស្គាល់ និងគោរពកិច្ចព្រមព្រៀងសិទ្ធិមនុស្សអន្តរជាតិនានា ហើយមាត្រា៤៥ វាក្យខ័ណ្ឌទី១ ចែងអំពីការបំបាត់ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ហើយថាអនុសញ្ញានេះមានអាទិភាពទៅលើច្បាប់ជាតិ បើទោះជាដូច្នោះក្តីក៏គណៈកម្មាធិការនៅមានការព្រួយបារម្ភថាបទបញ្ញត្តិនៃអនុសញ្ញានេះមិនអាចអនុវត្តដោយខ្លួនឯង ហើយមិនអាចយកទៅអនុវត្តដោយផ្ទាល់នៅក្នុងចំណាត់ការរបស់តុលាការបានឡើយ ។

១០- **គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគី សូមឱ្យចាត់វិធានការជាបន្ទាន់ ដើម្បីធានាថាអនុសញ្ញានេះត្រូវបានយកទៅអនុវត្តទាំងស្រុងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដោយរួមទាំងតាមរយៈការបោះពុម្ពផ្សាយនៅក្នុងរាជកិច្ច និងការដាក់បញ្ចូលបញ្ញត្តិនៃអនុសញ្ញានេះទាំងស្រុងទៅក្នុងច្បាប់ជាតិ ដោយរួមទាំងតាមរយៈការបញ្ចូលទណ្ឌកម្មផ្សេងៗ តាមដែលអាចធ្វើទៅបាន។ គណៈកម្មាធិការក៏បានស្នើផងដែរឱ្យរដ្ឋភាគីអនុវត្តវិធានការផ្សេងៗ ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីអនុសញ្ញានេះដល់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីនានា ហើយដាក់បញ្ចូលអនុសញ្ញានេះទៅក្នុងកម្មវិធីសិក្សាស្តីពីសិទ្ធិមនុស្ស រួមទាំងសិទ្ធិនារី ដើម្បីធានាធ្វើយ៉ាង**

**ណាឱ្យបុគ្គលគ្រប់រូបយល់ដឹងអំពីស្មារតី គោលបំណង និងបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ហើយត្រូវបានយកទៅប្រើប្រាស់នៅក្នុងកិច្ចដំណើរការរបស់តុលាការ ។**

១១- គណៈកម្មាធិការមានការព្រួយបារម្ភថា មិនមានកំណត់និយមន័យជាក់ច្បាស់អំពីចរិត និងទ្រង់ទ្រាយនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ស្របតាមមាត្រា១ នៃអនុសញ្ញានេះ ដែលហាមមិនឱ្យមានការរើសអើសដោយផ្ទាល់ ឬដោយប្រយោលក្តី នៅក្នុងច្បាប់កម្ពុជា។ គណៈកម្មាធិការក៏មានការព្រួយបារម្ភថាមិនមានបញ្ញត្តិច្បាប់ណាមួយចែងអំពីវិធានការពិសេសបណ្តោះអាសន្ន។

**១២- គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគី សុំឱ្យដាក់បញ្ចូលទៅក្នុងច្បាប់ជាតិនូវនិយមន័យនៃពាក្យរើសអើងប្រឆាំងនឹងស្ត្រីភេទ ដ៏រីញពាក្យថាការរើសអើងដោយផ្ទាល់ ឬដោយមិនផ្ទាល់ ស្របតាមមាត្រា១នៃអនុសញ្ញានេះ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីឆ្លៀតឱកាសដែលមានកិច្ចដំណើរការធ្វើកំណែទម្រង់ច្បាប់ ធ្វើឱ្យមានសមិតភាព និងភាពស្របគ្នាទាំងស្រុងរវាងច្បាប់ជាតិ និងបទបញ្ញត្តិនានានៃអនុសញ្ញានេះ។ គណៈកម្មាធិការស្នើផងដែរឱ្យរដ្ឋភាគីដាក់បញ្ចូលនូវទណ្ឌកម្មសមស្រប ទៅក្នុងក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌចំពោះទង្វើរើសអើងប្រឆាំងនឹងស្ត្រីភេទ និងធានាឱ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះស្ត្រីដែលត្រូវគេរំលោភសិទ្ធិ។ គណៈកម្មាធិការស្នើថែមទៀត ឱ្យបង្កើតបញ្ញត្តិច្បាប់ស្តីពីវិធានការពិសេសបណ្តោះអាសន្ន ដើម្បីពន្លឿនភាពស្មើគ្នាតាមព្រឹត្តន័យ ស្របតាមមាត្រា៤.១ នៃអនុសញ្ញានេះ។**

១៣- គណៈកម្មាធិការមានការព្រួយបារម្ភអំពីគំរិត និងទំហំនៃកម្មវិធីផ្សេងៗសំរាប់ស្ត្រីនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ហើយមិនមានទិន្នន័យបង្ហាញអំពីលទ្ធផលនៃការអនុវត្តឬប្រសិទ្ធិភាពនៃវិធានការផ្សេងៗ រួមទាំងការបញ្ជ្រាបវិស័យយេនឌ័រទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរអំពីការយកចិត្តទុកទៅលើសិទ្ធិស្ត្រី ដែលសិទ្ធិនេះអាចត្រូវបានគេធ្វើសមាហរណកម្មមិនបានគ្រប់គ្រាន់ទៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស។

**១៤- គណៈកម្មាធិការស្នើសុំឱ្យធ្វើសមាហរណកម្មបញ្ចូលការទទួលស្គាល់ និងការអនុវត្តន៍សិទ្ធិស្ត្រីទៅក្នុងយុទ្ធសាស្ត្រចតុកោណសំរាប់ការអភិវឌ្ឍន៍ ការងារ សមភាព និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ក្របខ័ណ្ឌនៃ**

**គោលការណ៍សមភាព និងភាពមិនរើសអើងដែលមានចែងនៅក្នុងអនុសញ្ញានេះ។ គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋភាគីធានាឱ្យមានការសម្របសម្រួលគ្រប់គ្រាន់នៅក្នុងកម្មវិធីគ្រប់វិស័យទាំងអស់ ដើម្បីឱ្យការអនុវត្តន៍គោលដៅមានភាពស្របគ្នាពាក់ព័ន្ធទៅនឹងការបញ្ជ្រាបយេនឌ័រ។ គណៈកម្មាធិការស្នើផងដែរឱ្យការអនុវត្តន៍កម្មវិធីទាំងអស់ គឺដើម្បីភាពជឿនលឿនរបស់ស្ត្រី រួមទាំងការខិតខំប្រឹងប្រែងបញ្ជ្រាបយេនឌ័រ ត្រូវស្ថិតក្រោម ការពិនិត្យឃ្លាំមើល ហើយប្រសិទ្ធិភាពនៃយន្តការជាតិដើម្បីភាពជឿនលឿនរបស់ស្ត្រី និងស្ថាប័នពាក់ព័ន្ធនានា ដូចជាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនិងក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រក៏ត្រូវស្ថិតក្រោមការពិនិត្យ និងវាយតំលៃផងដែរ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីផ្តល់ព័តិមានស្តីពីកំរិត និងទំហំ ក៏ដូចជាអំពីលទ្ធផល និងផលប៉ះពាល់នៃកម្មវិធីរបស់ខ្លួនសំរាប់ស្ត្រី និងការវាយតំលៃលើស្ថាប័នទទួលបន្ទុកកិច្ចការនារីនៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន។**

១៥- ទន្ទឹមនឹងការស្វាគមន៍ចំពោះការអនុម័តច្បាប់ស្តីពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ និងការធ្វើកំណែទម្រង់ក្រមព្រហ្មទណ្ឌនេះ គណៈកម្មាធិការមានការព្រួយបារម្ភថា បញ្ញត្តិទាំងឡាយនៅក្នុងច្បាប់ អាចដាក់កំរិតលើការអនុវត្តន៍របស់វា ក្នុងករណីនៃការរំលោភដោយសហព័ទ្ធ ហើយវាមិនបានរារាំងអតីតសហព័ទ្ធមិនឱ្យប្រព្រឹត្តរំលោភផងដែរ។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរ អំពីការជឿនលឿននៅមានកំរិតក្នុងការបង្ការ និងការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ និងឧបសគ្គធ្ងន់ធ្ងរសំរាប់ការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធិភាព។ ជាពិសេសទៅទៀត គណៈកម្មាធិការមានការព្រួយបារម្ភថា ស្ត្រីប្រឈមមុខទៅនឹងឧបសគ្គធំៗក្នុងការស្វែងរកយុត្តិធម៌ ដោយសារតែគ្មានការជឿទុកចិត្តលើប្រព័ន្ធតុលាការ ចៅក្រមធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌតាមទំនើងចិត្ត ដើម្បីជួយដល់ជនល្មើស ការរីករាលដាលនៃនិទណ្ឌភាពនៃជនល្មើស ជំនួយផ្នែកច្បាប់នៅមានកំរិត ហើយនិងលិខិតពេទ្យមានតំលៃខ្ពស់ ដែលគេតម្រូវឱ្យមានលិខិតនេះក្នុងករណីនៃការរំលោភសេពសន្ថវៈ និងការរំលោភផ្លូវភេទ។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរ អំពីការបណ្តោយឱ្យមានការរំលោភខាងយេនឌ័រនៅតែបន្តមានតទៅទៀត ហើយស្ត្រីភ័យខ្លាចមាន កេរ្តិ៍ឈ្មោះអាស្រូវ **(Stigma)** នៅពេលដែលពួកគេស្វែងរកដំណោះស្រាយ។

១៦- **គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគី ឱ្យចាត់ទុកជាបញ្ហាអាទិភាពខ្ពស់ចំពោះការអនុវត្តន៍គោលដៅទូលំទូលាយមួយ ដើម្បីបញ្ឈប់គ្រប់រូបភាពនៃអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ដោយរួមទាំងការអនុវត្តន៍**

និងការឃ្លាំមើលដ៏មានប្រសិទ្ធិភាពទៅលើច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ។ គណៈកម្មាធិការក៏បានស្នើយ៉ាងទទូចផងដែរឱ្យរដ្ឋភាគីផ្សព្វផ្សាយការយល់ដឹងដល់សាធារណៈជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងកម្មវិធីអប់រំថាអំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ រួមទាំងអំពើហឹង្សាក្នុងគ្រួសារផងដែរ ត្រូវហាមឃាត់ជាដាច់ខាត។ គណៈកម្មាធិការអំពាវនាវដល់រដ្ឋភាគីឱ្យបណ្តុះបណ្តាលតុលាការ មន្ត្រីអនុវត្តច្បាប់ អ្នកវិជ្ជាជីវៈច្បាប់ បុគ្គលិកសង្គមកិច្ច និងអ្នកផ្តល់សេវាសុខភាពអំពីច្បាប់ថ្មីស្តីពីការបង្ការអំពើហឹង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ និងដើម្បីធ្វើវេទយិតគ្រប់រូបភាពនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ ដើម្បីធានាថាជនប្រព្រឹត្តអំពើហឹង្សាទាំងនោះត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសប្រកបដោយប្រសិទ្ធិភាពទៅតាមទម្ងន់ទោស និងឱ្យបានទាន់ពេល។ គណៈកម្មាធិការក៏បានស្នើឱ្យបង្កើតស្ថាប័នមេធាវី ដើម្បីការពារជនរងគ្រោះទាំងនៅទីក្រុង និងទាំងនៅជនបទ ហើយតម្រូវថាការចេញលិខិតពេទ្យមិនត្រូវឱ្យគិតថ្លៃឡើយ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីរិះរកវិធីបង្កើនចំនួនចៅក្រម និងមន្ត្រីអនុវត្តច្បាប់ភេទស្រី ដែលជាមធ្យោបាយមួយក្នុងការជំរុញលើកទឹកចិត្តឱ្យស្ត្រីរាយការណ៍ពីករណីផ្សេងៗពាក់ព័ន្ធនឹងអំពើហឹង្សា។ គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋភាគីបង្កើតវិធានការគាំទ្រជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ រួមទាំងការគាំទ្រផ្នែកខាងជំរក ច្បាប់ ថ្នាំពេទ្យ និងចិត្តសាស្ត្រ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីអនុវត្តឱ្យបានពេញទំហឹងនូវអនុសាសន៍ទូទៅលេខ១៩ របស់គណៈកម្មាធិការក្នុងការខិតខំប្រឹងប្រែងបញ្ឈប់អំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ។

១៧- ដោយសំគាល់ឃើញពីតំលៃនៃមរតកវប្បធម៌នៃប្រទេសកម្ពុជា គណៈកម្មាធិការមានការព្រួយបារម្ភអំពីការបែងចែកយ៉ាងខ្លាំងអំពីតួនាទីខាងយេនឌ័រ ជាពិសេស វាបានចែងនៅក្នុងក្រមសីលធម៌ជាប្រពៃណីដែលគេស្គាល់ថា *ច្បាប់ស្រី* ដែលទទួលស្គាល់ការរើសអើងប្រឆាំងនឹងស្ត្រីភេទថាជារឿងស្របច្បាប់ ហើយរារាំងស្ត្រីមិនឱ្យប្រើប្រាស់សិទ្ធិរបស់ខ្លួន និងការទទួលបានសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រីនៅក្នុងសង្គមកម្ពុជា។

១៨- គណៈកម្មាធិការស្នើសុំឱ្យរដ្ឋភាគី រួមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងសង្គម ឱ្យធ្វើការវាយតំលៃយ៉ាងទូលំទូលាយមួយ ទៅលើក្រមសីលធម៌ជាប្រពៃណី ជាប្រយោជន៍ដើម្បីកំណត់ធាតុទាំងឡាយដែលនាំឱ្យមានការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហើយដែលជាឫសគល់នាំឱ្យស្ត្រីបាត់បង់អត្ថប្រយោជន៍នៅក្នុងវិស័យនានាដូចជា វិស័យអប់រំ ការងារ និងជីវភាពសាធារណៈ និងជីវភាពនយោបាយ ហើយដែលជាកត្តាកំណត់ឱ្យមានការរីករាលដាលនៃអំពើហឹង្សាលើមូលដ្ឋានយេនឌ័រ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីបញ្ឈប់ការ

**ផ្សព្វផ្សាយ និងការបង្រៀនអំពីគោលការណ៍ផ្សេងៗនៃក្រមសីលធម៌ប្រពៃណីដែលនាំឱ្យមានការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហើយជំនួសវិញដោយធ្វើការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងឱ្យសាធារណៈជនទូទៅយល់ដឹងអនុសញ្ញា និងគោលការណ៍សមភាពរវាងបុរស និងស្ត្រី។ គណៈកម្មាធិការសូមអំពាវនាវដល់រដ្ឋភាគីឱ្យអនុវត្តយុទ្ធនាការជាតិ និងធ្វើការយ៉ាងសកម្មឆ្ពោះទៅរកការលុបបំបាត់ការឱ្យតំលៃថោកទាបទាក់ទងនឹងមុខងារជាប្រពៃណីរបស់បុរស និងស្ត្រីនៅក្នុងគ្រួសារ និងនៅក្នុងសង្គមទាំងមូល ស្របតាមមាត្រា២ (ច) និងមាត្រា៥ (ក) នៃអនុសញ្ញា បង្កើនការយល់ដឹងថែមទៀតអំពីអត្ថន័យ និងខ្លឹមសារអំពីសិទ្ធិស្មើគ្នារបស់ស្ត្រីក្នុងវិស័យធំៗ និងបង្កើនការយល់ដឹងថា អំពើហឹង្សាលើស្ត្រីភេទ គឺជាការរំលោភទៅលើសិទ្ធិស្ត្រីដែលជាតំលៃខាងសង្គមយ៉ាងធំធេងសំរាប់សហគមន៍ទាំងមូល។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីផ្តល់ឱ្យខ្លួននៅក្នុងរបាយការណ៍លើកក្រោយអំពីលទ្ធផលនៃការវាយតំលៃទៅលើក្រមសីលធម៌ អំពីវិធានការនានាដែលបានចាត់ឡើងឆ្លើយតបនឹងលទ្ធផលទាំងនោះ និងឥទ្ធិពលរបស់វាទៅលើការផ្លាស់ប្តូរ និងការបន្ទាបបន្ថោក។**

១៩- នៅពេលដែលសំគាល់ឃើញមានការអនុវត្តន៏វិធានការនានា ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រួមមានការពិនិត្យច្បាប់ និងការអនុម័តកិច្ចព្រមព្រៀងអនុតំបន់ឆ្លងដែន គណៈកម្មាធិការសំដែងនូវកង្វល់អំពីការអនុវត្តន៏ច្បាប់នេះមិនទាន់ពេញលេញនៅឡើយ និទណ្ឌភាពរបស់អ្នកជួញដូរមនុស្ស និងការគ្មានទិន្នន័យច្បាស់លាស់អំពីករណីជួញដូរមនុស្ស។ គណៈកម្មាធិការមានការព្រួយបារម្ភណ៏អំពីស្លាកស្នាមទុរយសិរបស់ជនរងគ្រោះដោយការជួញដូរ និងការចាត់វិធានការមិនគ្រប់គ្រាន់ចំពោះការស្តានីតិសម្បទា និងការធ្វើសមាហ-រណកម្មទៅក្នុងសហគមន៏។ គណៈកម្មាធិការមានការព្រួយបារម្ភទៀតថា ស្ត្រី និងកុមារី ដែលទទួលរងការជួញដូរអាចត្រូវបានផ្តន្ទាទោសពីការរំលោភច្បាប់អន្តោប្រវេសន៏ ហើយពួកគេត្រូវក្លាយជាជនរងគ្រោះម្តងហើយម្តងទៀត ។ គណៈកម្មាធិការក៏បានសំគាល់ឃើញថា មានការរីករាលដាលខ្ពស់នូវការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារី ហើយភាពងាយរងគ្រោះរបស់គេនោះ ការឆ្លងជម្ងឺកាមរោគផ្សេងៗ និងមេរោគហ៊ីវ/ជម្ងឺអេដស៏។

២០- **គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីបង្កើនកិច្ចខិតខំប្រឹងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារី តាមរយៈការលើកឡើងអំពីប្រភពឬសគល់របស់វា និងដើម្បីចាត់វិធានការទប់ស្កាត់យ៉ាងទូលំទូលាយ រួមទាំងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រវេទយិតភាព**

**ខាងយេនឌ័រ យុទ្ធនាការផ្សព្វផ្សាយការយល់ដឹង និងការផ្តល់មធ្យោបាយផ្សេងៗនៃជីវព្រឹត្តិ។ គណៈកម្មាធិ-ការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីធានាថាជនទាំងឡាយដែលជួញដូរ និងធ្វើអាជីវកម្មលើស្ត្រី និងកុមារី ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសតាមច្បាប់ជាធរមាន។ គណៈកម្មាធិការស្នើសុំផងដែរឱ្យរដ្ឋភាគី បញ្ឈប់ការចោទប្រកាន់ជនរងគ្រោះដោយអំពើជួញមនុស្ស ពីបទអន្តោប្រវេសន៍ខុសច្បាប់។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីអនុវត្តវិធានការស្តារនីតិសម្បទា និងសមាហរណកម្មកុមារី និងស្ត្រីដែលជាជនរងគ្រោះដោយការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ។ គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគី អនុតំបន់ និងពហុភាគី ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីផ្តល់នៅក្នុងរបាយការណ៍លើកក្រោយរបស់ខ្លួន នូវព័ត៌មាន និងទិន្នន័យទូលំទូលាយស្តីពីការជួញស្ត្រី និងកុមារ និងឥទ្ធិពលនៃវិធានមួយចំនួន ដែលចាត់ឡើងចំពោះបញ្ហាទាំងនោះ។**

២១- គណៈកម្មាធិការមានការព្រួយបារម្ភទៀតថា ស្ត្រីកម្ពុជា ជាពិសេសស្ត្រីវ័យក្មេងដែលធ្វើអន្តោប្រវេសន៍ទៅប្រទេសជិតខាងនានា ដើម្បីស្វែងរកការងារធ្វើ ងាយស្រួលនឹងទទួលរងគ្រោះបំផុត ក្លាយជាជនរងគ្រោះតាមរូបភាពផ្សេងៗដូចជាអំពើហឹង្សា ការធ្វើអាជីវកម្មផ្លូវភេទ និងការជួញដូរមនុស្ស។

**២២- គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋភាគីផ្តោតការយកចិត្តទុកដាក់លើមូលហេតុ នៃការធ្វើអន្តោប្រវេសន៍របស់ស្ត្រី ហើយដើម្បីបង្កើតគោលនយោបាយ និងវិធានការនានា ដើម្បីការពារស្ត្រីអន្តោគ្រាមឱ្យជៀសផុតពីការធ្វើអាជីវកម្ម និងការរំលោភបំពាន។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីផ្តល់ព័ត៌មាន និងទិន្នន័យស្តីពីស្ត្រីអន្តោគ្រាម និងស្ថានភាពរបស់ពួកគេ នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ។**

២៣- ក្នុងខណៈដែលសំគាល់ឃើញថាមានការប្រឹងប្រែងជំរុញឱ្យមានការចូលរួមពីស្ត្រីនៅក្នុងក្រុមប្រឹក្សាសហគមន៍ គណៈកម្មាធិការសំដែងការព្រួយបារម្ភអំពីការដែលមានភាពជាតំណាងរបស់ស្ត្រីទាបនៅគ្រប់កំរិតទាំងក្នុងជីវភាពនយោបាយ ទាំងក្នុងមុខងារសាធារណៈ ជាពិសេសនៅក្នុងសភា ហើយការចូលរួមរបស់ស្ត្រីនៅក្នុងការបោះឆ្នោតនៅមានកំរិតទាប។ គណៈកម្មាធិការមានការព្រួយបារម្ភថែមទៀតអំពីការចូលរួមនៅមានកំរិតនៃស្ត្រីនៅក្នុងរដ្ឋបាលសាធារណៈ និងនៅក្នុងតុលាការគ្រប់ជាន់ថ្នាក់។

**២៤- គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីអនុវត្តផែនការយុទ្ធសាស្ត្រជាមួយនិងវិធានការនានា ជាប្រយោជន៍ឱ្យស្ត្រីជាប់ឆ្នោតនិងបានទទួលការតែងតាំងចូលបំរើការងារឱ្យកាន់តែច្រើនឡើងថែមទៀត ដោយរួមទាំងក្នុងវិស័យតុលាការផងដែរ ដូច្នេះហើយត្រូវពង្រឹងអនុវត្តមាត្រា៧ នៃអនុសញ្ញានេះ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីអនុវត្តវិធានការពិសេសបណ្តោះអាសន្ន ស្របតាមមាត្រា៤ កថាខ័ណ្ឌទី១ នៃអនុសញ្ញាជាមធ្យោបាយក្នុងការពន្លឿនដល់ការអនុវត្តន៍បញ្ញត្តិមាត្រា៧ នៃអនុសញ្ញានេះ តាមរយៈការបង្កើតតារាងពេលវេលា និងគោលដៅឱ្យស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការធ្វើសេចក្តីសំរេចចិត្តនៅគ្រប់កំរិតទាំងអស់។ គណៈកម្មាធិការក៏ស្នើផងដែរឱ្យរដ្ឋភាគីបើកវគ្គបណ្តុះបណ្តាលជំនាញអំពីភាពជាអ្នកដឹកនាំ និងការចរចាសំរាប់ស្ត្រីដែលជាអ្នកដឹកនាំបច្ចុប្បន្ន និងអនាគត។ គណៈកម្មាធិការស្នើថែមទៀតឱ្យអនុវត្តសកម្មភាពលើកកំពស់ការយល់ដឹងអំពីសារសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសំរេចចិត្តសំរាប់សង្គមទាំងមូល។**

២៥- គណៈកម្មាធិការសំដែងនូវការព្រួយបារម្ភអំពីអត្រាអនក្ខរភាពខ្ពស់នៃស្ត្រី ពិសេសស្ត្រីនៅតំបន់ជនបទ ស្ត្រីនៅក្នុងក្រុមជនជាតិភាគតិច ឬស្ត្រីពិការ អត្រាសិស្ស-និស្សិត ភេទស្រី និងភេទប្រុស ក្នុងការចុះឈ្មោះចូលរៀនមានគំលាតឆ្ងាយពីគ្នា ហើយសិស្ស-និស្សិតភេទស្រីដែលបញ្ឈប់ការសិក្សាមានចំនួនខ្ពស់។ គណៈកម្មាធិការមានការព្រួយបារម្ភអំពីផលប៉ះពាល់រយៈពេលដ៏យូរអង្វែងទៅលើសុខភាពរបស់ស្ត្រី សមត្ថភាពក្នុងការធ្វើសេចក្តីសំរេចចិត្ត និងការអភិវឌ្ឍន៍ជំនាញរបស់ខ្លួនសមស្របតាមតម្រូវការទីផ្សារ។ គណៈកម្មាធិការមានការព្រួយបារម្ភទៀតដែរអំពីការនៅកើតមានការបែកចែកផ្អែកយេនឌ័រជាមូលដ្ឋាននៅក្នុងវិស័យអប់រំនិងផលប៉ះពាល់ជាយកថាហេតុដល់ស្ត្រីសំរាប់ឱកាសបំរើមុខងារវិជ្ជាជីវៈ។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរអំពីការទទួលស្គាល់បែបនេះជារៀងរហូតមកនៅក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សានៅសាលារៀន។

**២៦- គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីចាត់ទុកជាបញ្ហាអទិភាពខ្ពស់ ចំពោះការកាត់បន្ថយអត្រាអនក្ខរកម្មរបស់ស្ត្រី ជាពិសេសស្ត្រីទាំងឡាយដែលរស់នៅតំបន់ជនបទ ស្ត្រីជាសមាជិកក្រុមជនជាតិភាគតិច ឬស្ត្រីជាជនពិការ។ គណៈកម្មាធិការស្នើយ៉ាងទទូចផងដែរឱ្យរដ្ឋភាគីចាត់ការជាបន្ទាន់នូវវិធានសមស្របនានា ដោយរួមទាំងវិធានការពិសេសបណ្តោះអាសន្ន ស្របតាមមាត្រា៤ កថាខ័ណ្ឌទី១ នៃអនុសញ្ញានេះ និងអនុសាសន៍ទូទៅលេខ២៥ របស់គណៈកម្មាធិការនេះ ដើម្បីលុបបំបាត់ភាពខុសគ្នាក្នុងអត្រាចុះឈ្មោះចូលរៀន**

**របស់សិស្ស-និស្សិត និងដើម្បីឱ្យកុមារីទទួលបានអប់រំកំរិតបឋមសិក្សាជាទូទៅ ស្របតាមមាត្រា១០ នៃអនុសញ្ញានេះ គោលដៅ និងផែនការយុទ្ធសាស្ត្រនៃសេចក្តីប្រកាសក្រុងប៉េកាំង និងវិធិការសំរាប់សកម្មភាព និងគោលការណ៍ទី២ និងទី៣ នៃគោលដៅអភិវឌ្ឍន៍សំរាប់សហសវត្ស។ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីដោះស្រាយប្រកបដោយប្រសិទ្ធិភាពឧបសគ្គទាំងឡាយដែលរារាំងដល់ក្មេងស្រី មិនឱ្យបន្តការសិក្សាអប់រំរបស់ខ្លួន ជាអាទិ៍ការជំរុញ ឬបង្ខំឱ្យក្មេងស្រីរៀបការមុនអាយុកំណត់។ គណៈកម្មាធិការក៏បានស្នើផងដែរ ឱ្យរដ្ឋភាគីជំរុញយ៉ាងសកម្មឱ្យមានការជ្រើសរើសផ្នែកអប់រំ និងជំនាញវិជ្ជាជីវៈដល់ស្ត្រី។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីពិនិត្យឡើងវិញ នូវកម្មវិធីសិក្សា និងសៀវសិក្សា ដើម្បីលុបបំបាត់ទំលាប់រើសអើងខាងយេនឌ័រ។**

២៧- គណៈកម្មាធិការសំដែងនូវការព្រួយបារម្ភអំពីការបែងចែកការងារ និងការដាក់ស្ត្រីនៅក្នុងផ្នែកបុគ្គលិក-កម្មករដែលត្រូវទទួលប្រាក់បៀវត្សទាប និងផ្នែកការងារគ្មានជំនាញ។ គណៈកម្មាធិការមានការព្រួយបារម្ភជាពិសេសអំពីភាពមិនច្បាស់លាស់នៅក្នុងច្បាប់ការងារ និងភាពទន់ខ្សោយក្នុងការអនុវត្តន៍ច្បាប់ការងារ ការមិនដាក់ទណ្ឌកម្មចំពោះការមិនគោរព និងគ្មានយន្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពដែលជាការរំលោភទៅលើស្ត្រីក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន ក្រោមមាត្រា៤ កថាខ័ណ្ឌទី២ និងមាត្រា១១ នៃអនុសញ្ញានេះ ដោយរួមទាំងសិទ្ធិមានប្រាក់បៀវត្សស្មើគ្នា សិទ្ធិសំរាកមាតុភាព សន្តិសុខសង្គម និងការការពារមិនឱ្យមានការយាយីផ្លូវភេទ។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរអំពីផលប៉ះពាល់ដែលអាចជាឧបសគ្គសំរាប់រយៈពេលវែងនៃការបញ្ឈប់កិច្ចព្រមព្រៀងពហុភាគីរបស់ស្ត្រីធ្វើការនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់។

**២៨- គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីសុំឱ្យពន្លឿន និងធានាឱ្យមានការចូលរួមដោយស្មើភាពគ្នាចំពោះស្ត្រី និងបុរសនៅក្នុងទីផ្សារការងារ។ គណៈកម្មាធិការអំពាវនាវថែមទៀត សូមឱ្យចាត់វិធានការដើម្បីធានាឱ្យស្ត្រីទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា និងមានតំលៃស្មើគ្នា និងទទួលបានសេវា និងអត្ថប្រយោជន៍ខាងសង្គមស្មើគ្នា។ គណៈកម្មាធិការជំរុញឱ្យរដ្ឋភាគីកំណត់និយមន័យឱ្យបានច្បាស់លាស់ចំពោះពាក្យថា ការងារដូចគ្នា និងការងារមានតំលៃស្មើគ្នា។ គណៈកម្មាធិការជំរុញឱ្យរដ្ឋភាគីកំណត់ទោសចំពោះការរើសអើងប្រឆាំងនឹងស្ត្រីភេទក្នុងវិស័យការងារ ទាំងក្នុងគ្រឹះស្ថានសាធារណៈ ទាំងក្នុងគ្រឹះស្ថាន**

**ឯកជន រួមទាំងការយាយីផ្លូវភេទ ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ និងយន្តការត្រួតពិនិត្យឱ្យមានប្រសិទ្ធិភាព ហើយដើម្បីធានាឱ្យស្ត្រីមានសិទ្ធិប្រើមធ្យោបាយដោះស្រាយ ដោយរួមទាំងជំនួយផ្នែកច្បាប់ផងដែរ។ គណៈកម្មាធិការជំរុញឱ្យរដ្ឋភាគីផ្សព្វផ្សាយអំពីច្បាប់ការងារដល់ស្ត្រី ដើម្បីឱ្យពួកគេយល់ដឹងអំពីសិទ្ធិរបស់ខ្លួន។ គណៈកម្មាធិការក៏បានស្នើឱ្យប្រើវិធានការពិសេសបណ្តោះអាសន្ននានា ស្របតាមមាត្រា៤ កថាខ័ណ្ឌទី១ នៃអនុសញ្ញានេះ និងអនុសាសន៍ទូទៅលេខ២៥ របស់គណៈកម្មាធិការ និងដើម្បីពន្លឿនឱ្យសំរេចបាននូវសមភាពតាមព្រឹត្តន័យនៅក្នុងវិស័យនៃការជ្រើសរើស បណ្តុះបណ្តាល និងការលើកស្ទួយស្របតាមមាត្រា១១ នៃអនុសញ្ញានេះ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីសរសេររៀបរាប់នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន អំពីផលប៉ះពាល់រយៈពេលយូរអង្វែង នៃការបញ្ឈប់កិច្ចព្រមព្រៀងពហុភាគី ដែលប៉ះពាល់ជាអវិជ្ជមានដល់ស្ត្រីដែលបំរើការនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងដើម្បីផ្តល់ព័តិមានស្តីពីវិធានការផ្សេងៗ ដែលបានចាត់ឡើង ដើម្បីទប់ទល់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានណាមួយ។**

២៩- គណៈកម្មាធិការកត់សំគាល់ថា ទោះបីជាមានការកាត់បន្ថយនូវអត្រាមរណៈរបស់មាតាក៏ដោយ អត្រាមរណៈនៅតែមានកំរិតខ្ពស់គឺ ៤១៧ នាក់ ក្នុង១០០.០០០ នាក់នៃម្តាយពេលប្រសូតបុត្រ មូលហេតុចម្បងគឺការខ្វះសេវាសង្គ្រោះបន្ទាន់នៅពេលសំរាលកូន។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរថា ការសំរាលកូន ចំនួនតែ១០ ភាគរយប៉ុណ្ណោះដែលធ្វើឡើងនៅមណ្ឌលសុខភាព។

៣០- **គណៈកម្មាធិការស្នើសុំឱ្យរដ្ឋភាគីពិនិត្យ និងដោះស្រាយការលំបាកក្នុងការទទួលបានសេវាសំរាលកូន ហើយស្នើឱ្យ (ក) បង្កើតផែនការយុទ្ធសាស្ត្រមួយដើម្បីកាត់បន្ថយអត្រាមរណៈនៃមាតា និងអត្រានៃស្ត្រីមានជំងឺ តាមរយៈនោះរដ្ឋភាគីត្រូវផ្តល់សេវាដែលមានគុណភាព និងឱ្យបានច្រើនថែមទៀតទៅគ្រប់ខេត្តទាំងអស់ ដូចជាសេវាមុន និងក្រោយពេលសំរាលកូន និងសេវាសង្គ្រោះបន្ទាន់ក្នុងពេលសំរាលកូន (ខ) បង្កើតសេវាបញ្ជូនស្ត្រីមានផ្ទៃពោះទៅសេវាសម្ភព (គ) កំណត់ពេលសំរាប់ការកាត់បន្ថយអត្រាមរណៈនៃមាតា និង (ឃ) ធ្វើការរៃអង្គាសថវិកាចាំបាច់ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីអនុវត្តកម្មវិធីនេះ។**

៣១- គណៈកម្មាធិការសំដែងនូវការព្រួយបារម្ភអំពីភាពក្រីក្រមានកំរិតខ្ពស់ ក្នុងចំណោមស្ត្រីនៅជនបទ ដែលបង្កើតបានជាចំនួនភាគច្រើននៃស្ត្រីនៅក្នុងប្រទេស។ ទន្ទឹមនឹងសង្កេតឃើញមានការខិតខំប្រឹងប្រែងក្នុងការ

ផ្តល់សិទ្ធិបុរិមាទៅឱ្យគ្រួសារដែលស្ត្រីជាមេគ្រួសារ ក្នុងការបែងចែកដីធ្លីក្រោមច្បាប់ភូមិបាល គណៈកម្មាធិការមានការព្រួយបារម្ភអំពីការអនុវត្តន៍ទូទៅនៃច្បាប់ភូមិបាល ។ គណៈកមាធិការមានការព្រួយបារម្ភផងដែរថា ស្ត្រីខ្វះការយល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងការយល់ដឹងអំពីច្បាប់ និងអំពីនីតិវិធីចុះបញ្ជីដីធ្លី ។ គណៈកម្មាធិ-ការមានការព្រួយបារម្ភជាពិសេសអំពីសភាពការណ៍ដែលស្ត្រីជាមេគ្រួសារគ្មានរបររកស៊ីចិញ្ចឹមជីវិត ដោយសារក្រុមហ៊ុនឯកជននានា បានរឹបអូសយកដីធ្លីពីពួកគេ និងការមិនឱ្យពួកគេចូលរួមធ្វើសេចក្តីសំរេចចិត្តពាក់ព័ន្ធនឹងការបែងចែកដីធ្លី ។

៣២- **គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីយកចិត្តទុកដាក់ជាពិសេស ចំពោះស្ថានភាពស្ត្រីនៅជនបទ ដើម្បីពង្រឹងការអនុវត្តន៍មាត្រា១៤ នៃអនុសញ្ញានេះ ដើម្បីធានាថាស្ត្រីនៅជនបទបានទទួលសេវាអប់រំ និងសេវាសុខភាព និងការសំរួលផ្នែកឥណទាន ហើយឱ្យពួកគេចូលរួមយ៉ាងពេញទំហឹងក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ គណៈកម្មាធិការស្នើយ៉ាងទទូចផងដែរឱ្យរដ្ឋភាគីផ្សព្វផ្សាយព័ត៌មានស្តីពីច្បាប់ភូមិបាល និងនីតិវិធីចុះបញ្ជីដីធ្លី និងដើម្បីចាត់វិធានការសមស្រប ដើម្បីលុបបំបាត់រាល់ទំរង់នៃការរើសអើងពាក់ព័ន្ធនឹងកម្មសិទ្ធិ និងការគ្រប់គ្រងដីធ្លីដោយស្ត្រី ។ គណៈកម្មាធិការអំពាវនាវផងដែរ ឱ្យរដ្ឋភាគីចាត់ទុកជាបញ្ហាអាទិភាពចំពោះស្ត្រីនៅជនបទ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលុបបំបាត់ភាពក្រីក្រ ។**

៣៣- ទន្ទឹមនឹងកត់សំគាល់ឃើញថាមានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ គណៈកម្មាធិការមានការព្រួយបារម្ភអំពីការអនុវត្តន៍ច្បាប់នេះមិនបានគ្រប់គ្រាន់ និងយន្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពទៅលើបញ្ហានេះ ។ គណៈកម្មាធិការមានការព្រួយបារម្ភថាកត្តាប្រពៃណី និងវប្បធម៌រារាំងស្ត្រីមិនឱ្យអនុវត្តសិទ្ធិរបស់ខ្លួនបានពេញលេញនៅក្នុងគ្រួសារ ជាពិសេសសិទ្ធិចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ដោយសេរី និងដោយមានការព្រមព្រៀងទាំងស្រុង ដោយមានចែងនៅក្នុងមាត្រា១៦ នៃអនុសញ្ញានេះ ។ គណៈកម្មាធិការមានការព្រួយបារម្ភផងដែរអំពីភាពខុសគ្នារវាងអាយុរបស់បុរស និងស្ត្រី ដែលអាចចុះកិច្ចសន្យាអាពាហ៍ពិពាហ៍បាន ។

៣៤- **គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីផ្សព្វផ្សាយព័ត៌មានទូទៅអំពីច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងដោះស្រាយកត្តាប្រពៃណី និងវប្បធម៌ ដែលរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីបង្កើនអាយុអប្បបរមានៃការរៀបអាពាហ៍ពិពាហ៍សំរាប់ស្ត្រី និងបុរសមកត្រឹមអាយុ**

១៨ ឆ្នាំ ដើម្បីឱ្យស្របតាមមាត្រា១៦ នៃអនុសញ្ញានេះ និង អនុសាសន៍ទូទៅរបស់គណៈកម្មាធិការលេខ២១ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

៣៥- គណៈកម្មាធិការសំដែងនូវការព្រួយបារម្ភអំពីស្ត្រីក្នុងក្រុមជនជាតិភាគតិច និងស្ត្រីពិការទាំងឡាយ ដែលប្រឈមមុខការរើសអើងតាមរូបភាពផ្សេងៗ ពាក់ព័ន្ធនឹងសិទ្ធិអប់រំ សិទ្ធិការងារ និងសិទ្ធិថែទាំសុខភាព និងជាជនរងគ្រោះដោយអំពើហឹង្សា ។ គណៈកម្មាធិការមានការសោកស្តាយដោយសារខ្វះព័ត៌មាន និងទិន្នន័យអំពីក្រុមស្ត្រីទាំងនោះ នៅក្នុងរបាយការណ៍ ។

៣៦- គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋភាគីយកចិត្តទុកដាក់ធ្វើសមាហរណកម្មស្ត្រីពិការ និងស្ត្រីក្នុងក្រុមជនជាតិភាគតិចទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីជាតិនានា ព្រមទាំងអនុវត្តវិធានការមួយចំនួន ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងក្រុមស្ត្រីទាំងនោះ ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីផ្តល់ នៅក្នុងរបាយការណ៍លើក្រោយរបស់ខ្លួន នូវទិន្នន័យ និងព័ត៌មានស្តីពីស្ថានភាពស្ត្រីពិការ និងស្ត្រីក្នុងក្រុមជនជាតិភាគតិច រួមទាំងបញ្ហាពាក់ព័ន្ធការអប់រំ ការងារ និងការថែទាំសុខភាព ។

៣៧- គណៈកម្មាធិការជំរុញលើកទឹកចិត្តឱ្យរដ្ឋភាគីផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញានេះ និងទទួលយកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន នូវវិសោធនកម្មមាត្រា២០ កថាខ័ណ្ឌទី១ នៃអនុសញ្ញា នេះពាក់ ព័ន្ធនឹងពេលប្រជុំរបស់គណៈកម្មាធិការ ។

៣៨- គណៈកម្មាធិការស្នើយ៉ាងទទូចឱ្យរដ្ឋភាគីប្រើប្រាស់ឱ្យបានពេញលេញ នៅក្នុងការអនុវត្តន៏កាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះ នូវសេចក្តីប្រកាសទីក្រុងប៉េកាំង និងវេទិកាសកម្មភាព ដែលពង្រឹងបន្ថែមទៅលើការអនុវត្តន៏បទបញ្ញត្តិនៃអនុសញ្ញានេះ ហើយស្នើឱ្យរដ្ឋភាគីដាក់បញ្ចូលព័ត៌មានពាក់ព័ន្ធបញ្ហាទាំងនេះ ទៅក្នុងរបាយការណ៍តាមកាលកំណត់របស់ខ្លួនលើកក្រោយ ។

៣៩- គណៈកម្មាធិការបានកត់សំគាល់ថា ការអនុវត្តន៏អនុសញ្ញាឱ្យបានពេញលេញនិងមានប្រសិទ្ធិភាព គឺមិនអាចអាក់ខានបានឡើយសំរាប់ការសំរេចបាននូវគោលដៅអភិវឌ្ឍន៏សហសវត្ស ។ គណៈកម្មាធិការអំពាវនាវ

ឱ្យធ្វើសមាហរណកម្មវិស័យយេនឌ័រ និងឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីបញ្ញត្តិដែលចែងនៅក្នុងអនុសញ្ញានេះទៅក្នុងរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ដែលមានបំណងសំរេចឱ្យបាននូវគោលដៅអភិវឌ្ឍសហសវត្ស ហើយស្នើសុំឱ្យរដ្ឋភាគីបញ្ចូលព័ត៌មានទាំងនោះនៅក្នុងរបាយការណ៍លើកក្រោយរបស់ខ្លួន។

៤០- គណៈកម្មាធិការកត់សំគាល់ថា ការប្រកាន់ខ្ជាប់របស់រដ្ឋភាគីចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិធំៗចំនួនប្រាំពីរ[១] គឺជាការពង្រឹងថែមទៀត ឱ្យស្ត្រីអាចប្រើប្រាស់សិទ្ធិ និងសេរីភាពជាមូលដ្ឋាននៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅរបស់ខ្លួន។ ហេតុដូច្នេះ គណៈកម្មាធិការជំរុញលើកទឹកចិត្តឱ្យរដ្ឋាភិបាលកម្ពុជាពិនិត្យពិចារណាលើការផ្តល់សច្ចាប័នលើសន្ធិសញ្ញា ដែលកម្ពុជាមិនទាន់ចូលជាភាគីនៅឡើយ នោះគឺអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រប់រូបនៃគ្រួសាររបស់ពួកគេ (ICPRAM WMTF)។

៤១- គណៈកម្មាធិការស្នើឱ្យធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា អំពីសេចក្តីផ្តល់មតិចុងក្រោយ ដើម្បីធ្វើឱ្យប្រជាជន រួមទាំងមន្ត្រីរដ្ឋាភិបាល អ្នកនយោបាយ សមាជិកសភា អង្គការស្ត្រី និងអង្គ-ការសិទ្ធិមនុស្សនានាយល់ដឹងអំពីវិធានការដែលបានចាត់ឡើង ក្នុងការធានានូវសមភាពស្ត្រីតាមនីតិន័យ និងតាមព្រឹត្តន័យ ព្រមទាំងវិធានការផ្សេងៗទៀត ដែលតម្រូវឱ្យមានពាក់ព័ន្ធនឹងបញ្ហានោះ។ គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីបន្តផ្សព្វផ្សាយឱ្យបានទូលំទូលាយថែមទៀត ជាពិសេស ដល់អង្គការស្ត្រី និងអង្គការសិទ្ធិមនុស្សនានា អំពីអនុសញ្ញា និងពិធីសារបន្ថែមនៃអនុសញ្ញានេះ អនុសាសន៍ទូទៅរបស់គណៈកម្មាធិការ សេចក្តីប្រកាសទីក្រុងប៉េកាំង និងវេទិកាសកម្មភាព និងលទ្ធផលនៃសម័យប្រជុំពិសេសលើកទីម្ភៃបីរបស់មហាសន្និបាតលើប្រធានបទ " ស្ត្រីឆ្នាំ២០០០: សមភាពយេនឌ័រ ការអភិវឌ្ឍន៍ និងសន្តិភាពសំរាប់សតវត្សទីម្ភៃមួយ" ។

---

[១] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR), កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR), អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD), អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW), អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (CAT), អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC), អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រប់គ្រប់រូបនៃគ្រួសាររបស់ពួកគេ (ICPRAMWMTF).

៤២- គណៈកម្មាធិការស្នើឱ្យរដ្ឋភាគីឆ្លើយតបចំពោះការព្រួយបារម្ភទាំងឡាយ ដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីផ្តល់មតិចុងក្រោយនេះ នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ ក្រោមមាត្រា១៨ នៃអនុសញ្ញានេះ។ គណៈកម្មាធិការអញ្ជើញរដ្ឋភាគីឱ្យដាក់ស្នើរបាយការណ៍តាមកាលកំណត់លើកទីបួនរបស់ខ្លួន ដែលត្រូវដល់ពេលកំណត់នៅខែវិច្ឆិកា ឆ្នាំ២០០៥ និងរបាយការណ៍តាមកាលកំណត់លើកទីប្រាំរបស់ខ្លួន ដែលត្រូវដល់ពេលកំណត់នៅខែវិច្ឆិកា ឆ្នាំ២០០៩ នៅក្នុងរបាយការណ៍បូកសរុបក្នុងឆ្នាំ២០០៩។